THE SCHOOL DISTRICT OF
PHILADELPHIA

William R. Hite Jr., Ed.D
អគ្គនាយក

ខែវិច្ឆិកា ឆ្នាំ ២០១៨

ជូនចំពោះសិស្ស ថ្នាក់ទី ៧៖

តើអ្នកដឹងទេថាហេតុអ្វីបានជាឆ្នាំនេះមានសារៈសំខាន់សម្រាប់អ្នក? គឺដោយសារតែ ពិន្ទុ ពិន្ទុនៃការប្រឡង PSSA និង កំណត់ហេតុនៃ អាកប្បកិរិយា និង វត្តមានអវត្តមាន ដែលអ្នកបានទទួលនៅឆ្នាំនេះ នឹងដើរតួយ៉ាងសំខាន់ក្នុងការសម្រេចថាតើអ្នកនឹងទៅរៀននៅវិទ្យាល័យណាមួយនៅឆ្នាំក្រោយនេះ។ យើងដឹងថាអ្នកចង់ធ្វើឱ្យបានល្អ ហើយបើសិនជាអ្នកបានពិន្ទុសុទ្ធតែ A's និង B's ទាំងអស់ មានអវត្តមានតិចជាង ៥ ដង រក្សាអាកប្បកិរិយាបានល្អ និង ទទួលបានពិន្ទុនៃការប្រឡងល្អ—អ្នកនឹងមានឱកាសអាចជ្រើសរើសក្នុងចំណោមវិទ្យាល័យជាង ១០០ តាមរយៈដំណើរការនៃការជ្រើសរើសសាលារៀន។

យើងមិនអាចបញ្ជាក់ពីសារៈសំខាន់នេះឱ្យបានគ្រប់គ្រាន់ទេ៖ នេះគឺជាឆ្នាំដែលអ្នកត្រូវបង្ហាញថាអ្នកគឺជាសិស្សដែលលេចធ្លោ។ ខិតខំរៀនសូត្រ យកចិត្តទុកដាក់ស្តាប់នៅក្នុងថ្នាក់ ធ្វើកិច្ចការដែលគ្រូឱ្យយកទៅធ្វើនៅផ្ទះរបស់អ្នក និង ប្រគល់ឱ្យគ្រូឱ្យទាន់ពេលវេលា មកសាលាឱ្យទាន់ពេលវេលា និង ប្រើវិធីចាស់ទុំក្នុងការដោះស្រាយជម្លោះជាមួយមិត្តភ័ក្តរបស់អ្នក។ នេះគឺជាវិធីដែលអ្នកនឹងទទួលបានជោគជ័យនៅក្នុងឆ្នាំនេះ និង ទៅអនាគត។

ក្រសួងមានវិទ្យាល័យសម្រាប់ជ្រើសរើសដែលគួរឱ្យចាប់អារម្មណ៍ជាច្រើន។ ឥឡូវនេះគឺជាពេលដ៏ល្អសម្រាប់អ្នកចាប់ផ្តើមស្វែងយល់ពីជម្រើស និង គិតពីផែនការទៅអនាគត របស់អ្នក។ អ្នកអាចដាក់ពាក្យសុំចូលរៀននៅឆ្នាំក្រោយ ទៅប្រាំ (៥) វិទ្យាល័យ របស់ក្រសួង ហេតុនេះសូមពិគ្រោះជាមួយ អ្នកផ្តល់ឱវាទ ឪពុកម្តាយ ឬ មនុស្សពេញវ័យណាដែលយកចិត្តទុកដាក់នឹងអ្នក អំពី ប្រភេទនៃវិទ្យាល័យដែលអ្នកចង់ទៅរៀន។ បញ្ជីឈ្មោះវិទ្យាល័យ របស់ក្រសួងអប់រំ អាចជួយអ្នកក្នុងការស្វែងយល់អំពីជម្រើសវិទ្យាល័យរបស់អ្នក។ អ្នកអាចមើលបញ្ជីឈ្មោះដោយចូលទៅ schoolselect.philasd.org ហើយចុចលើបណ្តាញតភ្ជាប់ទៅនឹងបញ្ជីឈ្មោះវិទ្យាល័យ។

ខ្ញុំចង់ឱ្យអ្នកខំឱ្យអស់ពីសមត្ថភាពរបស់អ្នក នៅឆ្នាំនេះ និង ធ្វើការសម្រេចចិត្តល្អៗ ដែលអាចជួយអ្នកឈានដល់កម្រិតបន្ទាប់។ នាយកសាលា អ្នកផ្តល់ឱវាទ គ្រូបង្រៀន ឪពុកម្តាយ ឬ អាណាព្យាបាល របស់អ្នក នៅទីនេះដើម្បីជួយអ្នក។

ខ្ញុំសូមជូនពរឱ្យអ្នកបន្តការទទួលជោគជ័យ!

ដោយសេចក្តីស្រឡាញ់រាប់អាន

William R. Hite Jr., Ed.D.

WRH/dpw

*Translation & Interpretation Center*
*11/2018*

*7th Grade Letter*
*Khmer*